ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

partners for prevention

# ការវាយតម្លៃគម្រោង "ឆ្ពោះទៅកាន់អនាគតរបស់យើង៖ "អភិវឌ្ឍន៍ទំនាក់ទំនងប្រកបដោយផាសុកភាព និងភាពរីករាយ អន្តរាគមន៍ទប់ស្កាត់បឋម ជាមួយក្មេងជំទង់ និងអ្នកផ្តល់ការថែទាំ ក្នុងខេត្តកំពង់ចាម ប្រទេសកម្ពុជា



ក្មេងជំទង់ចូលរួមក្នុងគម្រោង "ឆ្ពោះទៅកាន់អនាគតរបស់យើង៖ អភិវឌ្ឍន៍ទំនាក់ទំនងប្រកបដោយផាសុកភាព និងភាពរីករាយ"

*រក្សាសិទ្ធិដោយ៖ដៃគូទប់ស្កាត់*

UNDP
*Empowered lives.
Resilient nations.*

UNFPA

UN WOMEN

UN VOLUNTEERS

Australian Aid

# មាតិកា


**បញ្ជីរាយនាមរូបភាព និងតារាង** ........ ២

**អារម្ភកថា** ........ ៣

**សេចក្តីថ្លែងអំណរគុណ** ........ ៤

**ពាក្យកាត់** ........ ៥

**សេចក្តីសង្ខេប** ........ ៦

**សេចក្តីផ្តើម** ........ ១៨

បរិបទនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ........ ១៨

បរិបទកម្ពុជា៖ឋានៈនិងឋានានុក្រមសង្គម ........ ១៩

អំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅកម្ពុជា ........ ២០

ហេតុផលសម្រាប់ការអន្តរាគមន៍ ........ ២២

ការអន្តរាគមន៍៖ឆ្ពោះទៅកាន់អនាគតរបស់យើង ........ ២៣

**ការវាយតម្លៃ** ........ ២៨

ការរៀបចំការសិក្សា ........ ២៨

នីតិវិធីក្នុងការសិក្សា និងការប្រមូលទិន្នន័យ ........ ២៩

ការពិចារណាអំពីក្រមសីលធម៌ ........ ៣១

ដំណើរការនិងការវិភាគទិន្នន័យ ........ ៣២

ដែនកំណត់សម្រាប់ការសិក្សា ........ ៣៣

ការសិក្សាបែបគុណភាព ........ ៣៣

ការសិក្សាបែបបរិមាណ ........ ៣៣

**លទ្ធផល** ........ ៤៣

ក្មេងវ័យជំទង់ ........ ៣៤

ការរៀបរាប់អំពីអ្នកចូលរួមក្នុងការសិក្សា ........ ៣៤

ការផ្លាស់ប្តូរឥរិយាបថ និងការប្រព្រឹត្ត ........ ៣៦

ការស្ម័គ្រចិត្ត ........ ៤៩

អ្នកចិញ្ចឹមបីបាច់ ........ ៥២

ការរៀបរាប់អំពីអ្នកចូលរួមក្នុងការសិក្សា ........ ៥២

ការផ្លាស់ប្តូរឥរិយាបថ និងការប្រព្រឹត្ត ........ ៥៤

ការស្ម័គ្រចិត្ត ........ ៧២

**មេរៀនបទពិសោធន៍** ........ ៧៤
**ការពិភាក្សា** ........ ៨៨
**សេចក្តីសន្និដ្ឋាន** ........ ១០១
ឧបសម្ព័ន្ធ ១៖ លទ្ធផលបែបពិពណ៌នានៃការអង្កេតដើមគ្រា និងចុងគ្រា ........ ១០៣
ឧបសម្ព័ន្ធ ២ ៖ កម្រងសំណួរសម្រាប់ការសិក្សាស្រាវជ្រាវបែបគុណវិស័យ (អ្នកចូលរួម អ្នកសម្របសម្រួល និងអ្នកគ្រប់គ្រងអន្តរាគមន៍) ........ ១០៨
ឧបសម្ព័ន្ធ៣៖ កំណត់ពន្យល់ដើម្បីសុំព័ត៌មាន និងការយល់ព្រម (អ្នកចូលរួម អ្នកសម្របសម្រួល និងអ្នកគ្រប់គ្រងអន្តរាគមន៍) ........ ១១៨
ឧបសម្ព័ន្ធ ៤៖ កម្រងសំណួរ ........ ១៣៧
ឧបសម្ព័ន្ធ ៥៖ ការណែនាំអំពីករណីសិក្សា ........ ១៥៦
ឧបសម្ព័ន្ធ ៦៖ ការពិពណ៌នាអំពីការអន្តរាគមន៍ និងទ្រឹស្តីនៃការផ្លាស់ប្តូរ ........ ១៦០
ឧបសម្ព័ន្ធ ៧៖ សេចក្តីសង្ខេប៖ ស្វែងយល់ពីឥទ្ធិពល/លទ្ធផលនៃអន្តរាគមន៍ ״ឆ្ពោះទៅកាន់អនាគតរបស់យើង៖ អភិវឌ្ឍន៍ទំនាក់ទំនងប្រកបដោយផាសុកភាព និងភាពរីករាយ״ ........ ១៦៦
ឧបសម្ព័ន្ធ ៨៖ លិខិតឯកភាពពីគណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាព ដែលទាក់ទងនឹងមនុស្សនៃក្រសួងសុខាភិបាល ........ ១៨២
**ឯកសារយោង** ........ ១៨៣

# បញ្ជីរាយនាមរូបភាព និងតារាង


រូបភាពទី ១៖ លំដាប់អាយុនៃអ្នកចូលរួមនៅការអង្កេតចុងគ្រា ........ ៣៤
រូបភាពទី ២៖ ចំនួនក្មេងប្រុស និងក្មេងស្រីចូលរួមក្នុងវគ្គសិក្សា ........ ៣៥
រូបភាពទី ៣: ឥរិយាបថប្រកបដោយសមធម៌យេនឌ័រ ........ ៣៨
រូបភាពទី ៤: ការទទួលយកឥរិយាបថហិង្សា ........ ៤៧
រូបភាពទី ៥: ក្មេងជំទង់ដែលរាយការណ៍ថាបានដឹងអំពីសេវាគាំទ្រ ........ ៤៩
រូបភាពទី ៦: ការចូលរួមក្នុងសកម្មភាពស្ម័គ្រចិត្តរយៈពេល ៦ ខែកន្លងមក ........ ៥១
រូបភាពទី ៧: ការបែងចែកអាយុនៃអ្នកចូលរួម ........ ៥២
រូបភាពទី ៨: ចំនួនវគ្គសិក្សាដែលបានចូលរួមដោយបុរសនិងស្ត្រី ........ ៥៣
រូបភាពទី ៩: អ្នកផ្តល់ការថែទាំដែលមានការយល់ដឹងអំពីសេវាកម្មគាំទ្រប្រឆាំងនឹងអំពើហិង្សា ........ ៧១
រូបភាពទី ១០: ការចូលរួមនៅក្នុងសកម្មភាពស្ម័គ្រចិត្តរយៈពេល ៦ ខែកន្លងមក ........ ៧៤
រូបភាពទី ១១៖ ទម្រង់អេកូឡូស៊ីសង្គម ........ ៩២

តារាងទី ១: កត្តាហានិភ័យដែលបានកំណត់ស្តីពីការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រី និង សមាសធាតុអន្តរាគមន៍ដែលនឹងដោះស្រាយកត្តាហានិភ័យទាំងនេះ ៖ ........ ២៤
តារាងទី ២: វិធីសាស្ត្រអន្តរាគមន៍ចម្រុះ ........ ២៦
តារាងទី ៣: ការចូលរួមក្នុងការវាយតម្លៃការសិក្សា ........ ២៩
តារាងទី ៤: ការសង្ខេបពីរបកគំហើញពាក់ព័ន្ធនឹងក្មេងជំទង់ ........ ៨៨
តារាងទី ៥: ការសង្ខេបពីរបកគំហើញពាក់ព័ន្ធនឹងអ្នកចិញ្ចឹមបីបាច់ក្មេងវ័យជំទង់ ........ ៩០
តារាងទី ៦: លទ្ធផលនៃកិច្ចអន្តរាគមន៍ ........ ៩៩
តារាងទី ៧៖ លទ្ធផលបែបពិពណ៌នានៃការអង្កេតដើមគ្រា និងចុងគ្រាសម្រាប់ក្មេងជំទង់ ........ ១០៣
តារាងទី ៨៖ លទ្ធផលបែបពិពណ៌នាអង្កេតចុងគ្រាសម្រាប់ក្មេងជំទង់ ........ ១០៤
តារាងទី ៩៖ លទ្ធផលបែបពិពណ៌នានៃការអង្កេតដើមគ្រានិងចុងគ្រាសម្រាប់អ្នកចិញ្ចឹមបីបាច់ ........ ១០៥
តារាងទី ១០៖ លទ្ធផលបែបពិពណ៌នានៃការអង្កេតចុងគ្រាសម្រាប់អ្នកចិញ្ចឹមបីបាច់ ........ ១០៦

# អារម្ភកថា

ការសិក្សាវាយតម្លៃចុងគ្រានេះត្រូវបានរៀបចំឡើងដោយកម្មវិធីដៃគូដើម្បីការទប់ស្កាត់ ដែលជាកម្មវិធីថ្នាក់តំបន់ផ្តោតលើការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅអាស៊ី និងប៉ាស៊ីហ្វិក និងមានការចូលរួមពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA) ភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women) និងអង្គការអ្នកស្ម័គ្រចិត្តសហប្រជាជាតិ (UNV)។

ការសិក្សានេះរៀបចំឡើងក្រោយពីបញ្ចប់ការអនុវត្តកិច្ចអន្តរាគមន៍/គម្រោងរយៈពេល១២ខែ ក្នុងការទប់ស្កាត់បឋមចំពោះអំពើហិង្សាលើស្ត្រីដែលផ្តោតលើ "ឆ្ពោះទៅកាន់អនាគតរបស់យើង៖ អភិវឌ្ឍទំនាក់ទំនងប្រកបដោយផាសុកភាព និងភាពរីករាយ" នៅក្នុងឃុំចំនួន៥ នៃស្រុកព្រៃឈរ ខេត្តកំពង់ចាម។ គម្រោងស្តីពីការទប់ស្កាត់បឋមនេះគឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗទាំង៥ នៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៤-២០១៨។ យុទ្ធសាស្ត្រទប់ស្កាត់បឋមនេះបានផ្តោតការយកចិត្តទុកដាក់ចំពោះក្មេងវ័យជំទង់ និងឪពុកម្តាយឬអ្នកថែទាំរបស់ពួកគេ ដើម្បីបង្កើនចំណេះដឹង និងជំនាញក្នុងការអភិវឌ្ឍឥរិយាបថប្រកបដោយសមធម៌ ទំនាក់ទំនងដែលគ្មានអំពើហិង្សា និងការណែនាំអំពីការអនុវត្តបែបវិជ្ជមានទាក់ទងនឹងបទដ្ឋានសង្គម។

ការសិក្សាវាយតម្លៃនេះមានគោលបំណងស្វែងយល់ដើម្បីកំណត់ពីភាពបត់បែន ការទទួលយក លទ្ធភាពទទួលបាន និងផលប៉ះពាល់នៃការអន្តរាគមន៍/គម្រោងដែលជាភស្តុតាងជាក់ស្តែងក្នុងការផ្តល់ព័ត៌មានសម្រាប់រៀបចំគោលនយោបាយ និងការអនុវត្តការទប់ស្កាត់បឋមនៅក្នុងប្រទេសកម្ពុជា តាមរយៈការស្វែងយល់ពីគោលគំនិត បទពិសោធន៍ និងផលប៉ះពាល់នៃកិច្ចអន្តរាគមន៍ក្នុងការទប់ស្កាត់បឋមចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

យើងសង្ឃឹមថា ព័ត៌មានដែលបង្ហាញនៅក្នុងរបាយការណ៍នេះនឹងជួយជំរុញ និងបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រីកាន់តែមានប្រសិទ្ធភាព។

ខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការ និងការខិតខំប្រឹងប្រែងរបស់កម្មវិធីក្នុងភាពជាដៃគូដើម្បីទប់ស្កាត់ ដែលជាកម្មវិធីថ្នាក់តំបន់ និងចូលរួមដោយភ្នាក់ងារអង្គការសហប្រជាជាតិជាច្រើន ជាពិសេសមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA)ប្រចាំនៅកម្ពុជាដែលគាំទ្រលើការសិក្សាវាយតម្លៃនេះ។ ក្រសួងកិច្ចការនារីមានមោទនភាពក្នុងការចែករំលែកលទ្ធផលនៃការសិក្សាវាយតម្លៃនេះដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។៚

ថ្ងៃ ព្រហស្បតិ៍ ៥រោច ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៨

ក.ស. រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហ៊ូ~សាមិត្ត

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណដល់លោក លោកស្រី ក្មេងស្រី និងក្មេងប្រុស មកពីខេត្តកំពង់ចាមដែលបានចូលរួម ចែករំលែកមេរៀនបទពិសោធន៍ដល់គម្រោង "ឆ្ពោះទៅកាន់អនាគតរបស់យើង ៖ ការអភិវឌ្ឍន៍ទំនាក់ទំនងប្រកបដោយផាសុកភាព និងភាពរីករាយ។ យើងសូមថ្លែងអំណរគុណផងដែរ ដល់កញ្ញា **ឃាង សន្តាបូរ៉ាម៉ាណា** អ្នកស្ម័គ្រចិត្តនៃមូនិធិអង្គការសហប្រជាជាតិ សម្រាប់ប្រជាជននៅកម្ពុជា និងក្រសួងកិច្ចការនារីកម្ពុជាដែលបានជួយសម្របសម្រួលក្នុងការប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវនេះ ។ សូមអរគុណក្រុមការងាររបស់ **ធីអិនអេស ខាន់ថាស** បានប្រមូលទិន្នន័យបែបបរិមាណ និង កញ្ញា **ស្រី អឿនចែម** និង **ឡាយ ហួសៅ** បានប្រមូលទិន្នន័យបែបគុណភាពនៅតាមមូលដ្ឋាន។ ខ្ញុំសូមថ្លែងអំណរគុណដល់កម្មវិធីដៃគូដើម្បីទប់ស្កាត់អំពើហិង្សានិងអង្គការមូនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជននៅកម្ពុជា ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស សម្រាប់ការប្រមូលទិន្នន័យទាំងនេះ ។ សូមអរគុណដល់លោកស្រី **KathyTaylor** និង **ផាន សុធា** ដែលបានផ្តល់ការ បណ្តុះបណ្តាលនិងគាំទ្រដល់ក្រុមប្រមូលទិន្នន័យ។ ព្រមទាំងសូមអរគុណដល់ក្រុមការងារ នៃអង្គការមូនិធិអង្គការសហប្រជាជាតិ សម្រាប់ប្រជាជននៅកម្ពុជា រួមមាន លោក **លឹម សាគី** លោកស្រី **អាំង សុខរើន** និងកញ្ញា **លឹម សេរីរ័ត្ន** និងក្រុមការងារនៃក្រសួងកិច្ចការនារី ដែលបានផ្តល់មតិយោបល់ដ៏មានតម្លៃលើរបាយការណ៍នៃការសិក្សានេះ ។

# ពាក្យកាត់

| | |
|---|---|
| CDHS | ការអង្កេតប្រជាសាស្ត្រ និងសុខភាពរបស់កម្ពុជា |
| FGD | ការពិភាក្សាជាមួយក្រុមគោលដៅ |
| HIV | មេរោគអេដស៍ |
| IDI | ការសម្ភាសន៍ស៊ីជម្រៅ |
| IPV | អំពើហិង្សាលើដៃគូស្និទ្ធស្នាល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| UNFPA | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UN MCS | ការសិក្សាពហុប្រទេសរបស់អង្គការសហប្រជាជាតិស្តីពីបុរស និងអំពើហិង្សា |
| UNV | អង្គការអ្នកស្ម័គ្រចិត្តសហប្រជាជាតិ |
| UN Women | ភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រី |
| VAWG | អំពើហិង្សាលើស្ត្រី និងក្មេងស្រី |
| WHO | អង្គការសុខភាពពិភពលោក |

# សេចក្តីសង្ខេប

## បរិបទនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅកម្ពុជា

នៅទូទាំងពិភពលោក អំពើហិង្សាលើស្ត្រី និងកុមារ នៅតែបន្តដែលបានបង្កឱ្យមានបញ្ហាសុខភាពសាធារណៈសិទ្ធិមនុស្សនិងបញ្ហាសង្គមយ៉ាងធ្ងន់ធ្ងរព្រមទាំងផ្តល់នូវផលវិបាកផ្នែកសុខភាពយ៉ាងទូលំទូលាយដល់ស្ត្រី និងក្មេងស្រី ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង ។

ការអង្កេតប្រជាសាស្ត្រ និងសុខាភាពកម្ពុជា ឆ្នាំ ២០១៤ (CDHS) បានរកឃើញថា ស្ត្រីប្រហែលជា ២០% (ដែលមានអាយុចន្លោះពី ១៥ ឆ្នាំ ដល់ ៤៩ ឆ្នាំ) បានទទួលរងនូវអំពើហិង្សាលើរាងកាយ យ៉ាងហោចណាស់១ដងក្នុងមួយជីវិតរបស់ពួកគេ និង ៦% នៃស្ត្រី បានទទួលរងនូវអំពើហិង្សាលើផ្លូវភេទនៅក្នុងជីវិតរបស់ពួកគេ។អំពើហិង្សាដែលបង្កពីដៃគូស្និទ្ធស្នាលក៏កាន់តែមានប្រេវ៉ាឡង់ខ្ពស់ផងដែរ[1]។យោងតាមលទ្ធផលនៃការអង្កេតថ្នាក់ជាតិរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០១៥ ស្តីពីបទពិសោធន៍ជីវិត និងសុខភាពស្ត្រី បានបង្ហាញថា មានស្ត្រី ២១% បានទទួលរងអំពើហិង្សាពីដៃគូលើផ្លូវកាយ ឬផ្លូវភេទ និង ៣២% បានទទួលរងអំពើហិង្សាពីដៃគូលើផ្លូវចិត្ត ។

លទ្ធផលនៃការសិក្សាពហុប្រទេសរបស់កម្មវិធីដៃគូដើម្បីទប់ស្កាត់នៃអង្គការសហប្រជាជាតិស្តីពីបុរស និងអំពើហិង្សា (UNMCS) ឆ្នាំ២០១៣នៅកម្ពុជា បានបង្ហាញថា បុរសជាងពាក់កណ្តាលបានប្រព្រឹត្តអំពើហិង្សាទៅលើដៃគូស្និទ្ធស្នាលរបស់ខ្លួនលើផ្លូវចិត្ត និង/ឬលើផ្នែកសេដ្ឋកិច្ច ក្នុងអំឡុងពេលមួយជីវិតរបស់ពួកគេ ។ បុរស ច្រើនជាងមួយភាគបី បានប្រព្រឹត្តអំពើហិង្សាលើដៃគូរបស់ខ្លួនផ្នែករាងកាយ និងផ្លូវភេទ ក្នុងជីវិតរបស់ពួកគេ ។ អត្រាប្រេវ៉ាឡង់នៃបុរសដែលរំលោភសេពសន្ថវៈលើអ្នកដែលមិនមែនជាដៃគូស្និទ្ធស្នាលរបស់ខ្លួនក្នុងមួយជីវិតរបស់ពួកគេមាន ៨% និង ៥% ទៀត គឺការចាប់រំលោភសេពសន្ថវៈជាក្រុមលើនារីម្នាក់។ គេបានរាយការណ៍ផងដែរថា បុរសច្រើនជាងពាក់កណ្តាល បានធ្វើការរំលោភបែបនេះ គឺនៅពេលដែលពួកគេមានវ័យជាក្មេងជំទង់ ។

## អន្តរាគមន៍៖ ការឆ្ពោះទៅកាន់អនាគតរបស់យើង

មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ក្នុងភាពជាដៃគូជាមួយភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រី (UN Women) និងអង្គការអ្នកស្ម័គ្រចិត្តសហប្រជាជាតិ (UNV) នៅកម្ពុជា រួមជាមួយក្រសួងកិច្ចការនារី ដោយទទួលបានការគាំទ្រពីកម្មវិធី ដៃគូដើម្បី

预览已结束，完整报告链接和二维码如下：
https://www.yunbaogao.cn/report/index/report?reportId=5_19499